ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

# ប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព) សម្រាប់ផលិតកម្ម និង អាជីវកម្មគ្រាប់ពូជស្រូវ





រៀបចំដោយ៖ អគ្គនាយកដ្ឋានកសិកម្ម

សហការគាំទ្រ និងឧបត្ថម្ភដោយ

Australian Aid

CAVAC Innovation in Agriculture

JICA

RSPP Quality Seed, Quality Rice

បោះពុម្ពលើកទី១ ចំនួន ១០០០ ក្បាល ក្រោមជំនួយរបស់កម្មវិធីកាវ៉ាក់

ខែ ឧសភា ឆ្នាំ ២០២២

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភានៅតែចាត់ទុកវិស័យកសិកម្ម ជាវិស័យអាទិភាពដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ ដោយមើលឃើញសក្តានុពលដ៏ធំធេងរបស់វិស័យកសិកម្មជាពិសេសដំណាំស្រូវ រាជរដ្ឋាភិបាលបានបង្ហាញពីជំហរគាំទ្រលើផលិតកម្មដំណាំស្រូវតាមរយៈគោលនយោបាយស្តីពី**ការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករនៅឆ្នាំ២០១០**។ ព្រមជាមួយនឹងកំណើនទាំងផលិតកម្ម និងការនាំចេញដែលមាននិន្នាការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ជាហេតុធ្វើឱ្យសេចក្តីត្រូវការគ្រាប់ពូជស្រូវគុណភាពល្អ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។

កន្លងមក ប្រទេសកម្ពុជាមិនទាន់មានប្រព័ន្ធត្រួតពិនិត្យនិងបញ្ជាក់គុណភាពពូជដំណាំគ្រប់ប្រភេទដែលកំពុងធ្វើចរាចរណ៍នៅលើទីផ្សារ ហើយមិនទាន់មានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យនិងបញ្ជាក់គុណភាពការធ្វើផលិតកម្មនិងអាជីវកម្មគ្រាប់ពូជដំណាំឱ្យពេញលេញ និងទូលំទូលាយ ដែលជាហេតុនាំឱ្យមានកង្វះគ្រាប់ពូជសុទ្ធមានគុណភាពល្អ សម្រាប់ដាំដុះ ហើយកសិករមិនសូវមានភាពជឿជាក់លើគុណភាពគ្រាប់ពូជដែលចរាចរនៅលើទីផ្សារ។

ដើម្បីបង្កើនជំនឿទុកចិត្ត និងទទួលបានពូជដំណាំមានគុណភាពល្អសម្រាប់ប្រើប្រាស់ **ប្រព័ន្ធធានាគុណភាពពូជដំណាំ** ដែលសរសេរអក្សរកាត់ **ប.គ.ព** ត្រូវបានរៀបចំឡើងដោយមានការផ្តល់ធាតុចូលសំខាន់ៗ និងចូលរួមកែលម្អពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អ្នកជំនាញមកពីនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី(CAVAC) ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិប្រចាំប្រទេសកម្ពុជា(IRRI-Cambodia) និងកម្មវិធីជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ(MAFF-NIO for Rice-SDP)។

សៀវភៅស្តីពី **ប្រព័ន្ធធានាគុណភាពពូជដំណាំ** នឹងផ្តល់នូវព័ត៌មានលម្អិតទាក់ទងទៅនឹងរចនាសម្ព័ន្ធ ប្រតិបត្តិ នីតិវិធី លក្ខណៈវិនិច្ឆ័យសម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យនិងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកដ្ឋានកសិកម្ម សូមថ្លែងអំណរគុណចំពោះក្រសួងការបរទេសនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី(DFAT) និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) ដែលបានឧបត្ថម្ភដល់ការរៀបចំចងក្រង និងបោះពុម្ពសៀវភៅនេះឡើងជាជំហ៊ានដំបូង។

អគ្គនាយកដ្ឋានកសិកម្មសូមស្វាគមន៍នូវរាល់យោបល់កែលម្អលើចំណុចខ្វះខាតពីសំណាក់អ្នកអាន ដើម្បីកែសម្រួលឱ្យសៀវភៅនេះកាន់តែមានប្រសិទ្ធភាព និងសង្គតិភាព នៅពេលបោះពុម្ពលើកក្រោយ ។

ថ្ងៃ សុក្រ ១៣ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២២

**អគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហិន ណាឡុយ**

# ក្រុមការងារបច្ចេកទេស ប.គ.៣

| ល.រ | ឈ្មោះ | តួនាទី | ស្ថាប័ន |
| --- | --- | --- | --- |
| ១ | ឯកឧត្តមបណ្ឌិត ងិន ឆាយ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម | អគ្គនាយកដ្ឋានកសិកម្ម |
| ២ | បណ្ឌិត គង់ គា | ប្រធាននាយកដ្ឋានដំណាំស្រូវ | អគ្គនាយកដ្ឋានកសិកម្ម |
| ៣ | លោក អោម ពេជ្រ | ប្រធាននាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៤ | លោកស្រី ស្រ៊ុន ខេម៉ា | អនុប្រធាននាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៥ | បណ្ឌិត ម៉ាក់ ច័ន្ទរតនា | អនុប្រធាននាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៦ | លោកស្រី ប៉ាន់ សុដាវី | ប្រធានការិយាល័យនៃនាយកដ្ឋានពូជដំណាំ | អគ្គនាយកដ្ឋានកសិកម្ម |
| ៧ | Mr. Edo Lin | ប្រធានផ្នែកភាពប្រកួតប្រជែង | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី ( CAVAC ) |
| ៨ | លោកស្រី ជី ពន្លឺ | ប្រធានសម្របសម្រួលផ្នែកភាពប្រកួតប្រជែង | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី ( CAVAC ) |
| ៩ | លោក កែន សិរីវឌ្ឍនា | ប្រធានសម្របសម្រួលភាគីពាក់ព័ន្ធ | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី ( CAVAC ) |
| ១០ | លោក សឹង ភូសនា | ប្រធានសម្របសម្រួលផ្នែកកសិកម្ម | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី ( CAVAC ) |
| ១១ | លោក សាក់ ជឿន | ទីប្រឹក្សា | គម្រោងជំរុញផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវ ( RSPP ) |
| ១២ | Mr. Masaru YAMAZAKI | ទីប្រឹក្សា | គម្រោងជំរុញផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវ ( RSPP ) |
| ១៣ | លោក អ៊ុច ចាន់ថុល | អ្នកគ្រប់គ្រងជាន់ខ្ពស់ | វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិប្រចាំកម្ពុជា ( IRRI Cambodia ) |
| ១៤ | លោក ឈិត ស៊ីថា | ទីប្រឹក្សាថ្នាក់ជាតិផ្នែកវិញ្ញាបនបត្រគ្រាប់ពូជ | កម្មវិធីជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( MAFF-NIO for Rice-SDP ) |

# ពាក្យបំព្រួញ

| | |
|---|---|
| CA | អង្គភាពមានសមត្ថកិច្ច |
| CAVAC | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី |
| DCS | នាយកដ្ឋានពូជដំណាំ |
| DFAT | ក្រសួងការបរទេសនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី |
| FAO | អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| IRRI | វិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ |
| ISTA | សមាគមវិភាគពូជដំណាំអន្តរជាតិ |
| JICA | ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត |
| QDS | ប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព) |
| Rice-SDP | កម្មវិធីជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ |
| RSPP | គម្រោងជំរុញផលិតកម្មនិងការប្រើប្រាស់គ្រាប់ពូជស្រូវ |

# មាតិកា


**សេចក្តីផ្តើម** ............ ១

**ផ្នែកទី១៖ រចនាសម្ព័ន្ធគ្រប់គ្រង ប.គ.ព សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ** ............ ២

១.១- អ្នកពាក់ព័ន្ធក្នុងការអនុវត្ត ប.គ.ព ............ ២

១.២- តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការអនុវត្ត ប.គ.ព ............ ២

១.៣- ប្រភេទពូជស្រូវអនុញ្ញាតឱ្យផលិត ............ ៥

១.៤- លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ............ ៥

១.៥- ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ............ ៥

១.៦- ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ ............ ៥

១.៧-ការអនុម័តមុនផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព ............ ៦

១.៨-ការផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព ............ ៦

១.៩-កម្រៃសេវាកម្ម ............ ៦

**ផ្នែកទី២៖ នីតិវិធីអនុវត្ត ប.គ.ព** ............ ៧

២.១- ការដាក់ពាក្យស្នើសុំ ............ ៧

២.២- ហេតុផលនៃការបដិសេធ ............ ៧

២.៣- សិទ្ធិក្នុងការប្តឹងជំទាស់ ............ ៨

២.៤- សេចក្តីប្រកាសអំពីផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ ............ ៨

២.៥- ការកំណត់ស្រែសម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ............ ៨

២.៦- ការផ្ទៀងផ្ទាត់ប្រភពគ្រាប់ពូជសម្រាប់ផលិតកម្មគ្រាប់ពូជ ............ ៨

២.៧- ការត្រួតពិនិត្យស្រែផលិតកម្មគ្រាប់ពូជស្រូវ ............ ៨

២.៨- ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ ............ ៩

២.៩- ការវិភាគគុណភាពគ្រាប់ពូជ ............ ១០

២.១០- សេចក្តីសម្រេចចុងក្រោយ ............ ១០

**ផ្នែកទី៣៖ លក្ខណៈវិនិច្ឆ័យសម្រាប់ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល** ............ ១២

៣.១- លក្ខខណ្ឌតម្រូវសម្រាប់ស្រែផលិតកម្មគ្រាប់ពូជ ............ ១២

៣.២- គម្លាតស្រែផលិតកម្មគ្រាប់ពូជ ............ ១២

៣.៣- ប្រភេទពូជលាយ........ ១២

៣.៤- ប្រភេទស្មៅហាមឃាត់........ ១២

៣.៥- ប្រភេទជំងឺហាមឃាត់........ ១៣

៣.៦- ដំណើរការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល........ ១៣

**ផ្នែកទី៤៖ ការយកសំណាកគ្រាប់ពូជនៅក្នុងឃ្លាំងសម្រាប់វិភាគគុណភាព**........ ១៤

៤.១- ឡូតិ៍គ្រាប់ពូជ និងការរៀបចំគ្រាប់ពូជក្នុងឃ្លាំង........ ១៤

៤.២- ការរៀបចំសំណាកសម្រាប់វិភាគ........ ១៤

**ផ្នែកទី៥៖ ស្តង់ដារគុណភាពគ្រាប់ពូជស្រូវតាមថ្នាក់**........ ១៦

**ផ្នែកទី៦៖ ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព**........ ១៦

**ឧបសម្ព័ន្ធ**........ ១៧

**ឧបសម្ព័ន្ធទី១**........ ១៨

**ឧបសម្ព័ន្ធទី២**........ ២១

**ឧបសម្ព័ន្ធទី៣**........ ២២

**ឧបសម្ព័ន្ធទី៤**........ ២៥

**ឧបសម្ព័ន្ធទី៥**........ ២៧

**គំនូសបំព្រួញនីតិវិធី ប.គ.ព សម្រាប់ផលិតកម្ម និងអាជីវកម្មគ្រាប់ពូជស្រូវ**........ ២៨

**សន្ទានុក្រម**........ ២៩

# សេចក្តីផ្តើម

អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) បានបោះពុម្ពសៀវភៅមគ្គុទេសក៍ស្តីពី **ប្រព័ន្ធធានាគុណភាពពូជដំណាំ** ដែលសរសេរអក្សរកាត់ **ប.គ.ព** នៅក្នុងឆ្នាំ២០០៦។ **ប.គ.ព** មានអត្ថប្រយោជន៍នៅក្នុងប្រទេសមួយចំនួនដែលមិនទាន់មានប្រព័ន្ធធានាគុណភាពពូជដំណាំ ជាពិសេសវិស័យសាធារណៈនៅមិនទាន់មានធនធានមនុស្សនិងហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ប្រតិបត្តិប្រព័ន្ធត្រួតពិនិត្យនិងបញ្ជាក់គុណភាពពេញលេញ បានទូលំទូលាយនៅឡើយ។ **ប.គ.ព** ត្រូវបានអនុវត្តដោគជ័យក្នុងប្រទេសមួយចំនួន ដូចជា៖ ប្រទេសហ្សាំប៊ៀ តង់សានី អ៊ុយហ្គង់ដា បង់ក្លាដែស នេប៉ាល់ និងឥណ្ឌា។

គោលនយោបាយពូជដំណាំនៅកម្ពុជា(២០១៦) ចែងថាគោលបំណងចម្បងនៃក្របខណ្ឌនិយ័តកម្មគឺដើម្បីលើកកម្ពស់ស្តង់ដារពូជដំណាំនិងប្រភេទពូជដំណាំនៅលើទីផ្សារ ហើយក៏ដើម្បីការពារកសិករនិងអ្នកពាក់ព័ន្ធដទៃទៀតចំពោះការក្លែងបន្លំដោយចេតនា។ ការដាក់ឱ្យប្រើប្រាស់ **ប.គ.ព** នៅពេលនេះ គឺជាជំហ៊ានដំបូងដើម្បីឆ្ពោះទៅរកក្របខ័ណ្ឌនិយ័តកម្មថ្មីពេញលេញស្របតាមច្បាប់និងគោលនយោបាយពូជដំណាំដែលបានរៀបចំនាពេលកន្លងមក ក៏ដូចជាជួយឱ្យឧស្សាហកម្មពូជដំណាំមានការរីកចម្រើនដើម្បីចូលរួមបង្កើនផលិតភាពផលិតកម្មកសិកម្មមួយកម្រិតថែមទៀត។

នៅក្នុងការអនុវត្ត **ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ អង្គភាពមានសមត្ថកិច្ចមានតួនាទីត្រួតពិនិត្យគុណភាពផលិតកម្មគ្រាប់ពូជនៅទីវាលចំនួន១០% នៃផ្ទៃដីផលិតកម្មសរុប តាមប្រភេទពូជនីមួយៗ និងត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវសម្រេចសម្រាប់ធ្វើអាជីវកម្មក្នុងកម្រិតអប្បបរមា១០%នៃឡូត៍គ្រាប់ពូជតាមប្រភេទពូជ និងថ្នាក់គ្រាប់ពូជនីមួយៗដោយចៃដន្យ។ រីឯអ្នកផលិតគ្រាប់ពូជ និងអាជីវករត្រូវទទួលខុសត្រូវចំពោះគុណភាពគ្រាប់ពូជស្រូវស្របតាមស្លាកសញ្ញាបញ្ជាក់គុណភាពត្រឹមត្រូវ ដែលចេញដោយអគ្គនាយកដ្ឋានកសិកម្ម។

# ផ្នែកទី១៖ រចនាសម្ព័ន្ធគ្រប់គ្រង ប.គ.ព សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ

## ១.១- អ្នកពាក់ព័ន្ធក្នុងការអនុវត្ត ប.គ.ព

### ១.១.១- នាយកដ្ឋានពូជដំណាំ

**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម ជាអង្គភាពមានសមត្ថកិច្ចថ្នាក់ជាតិជំរុញការអនុវត្ត **ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.១.២- នាយកដ្ឋានដំណាំស្រូវ

**នាយកដ្ឋានដំណាំស្រូវ**នៃអគ្គនាយកដ្ឋានកសិកម្ម ជាអង្គភាពជំនាញក្នុងការបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវតាម **ប.គ.ព** ដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

### ១.១.៣- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ជាអង្គភាពមានសមត្ថកិច្ចថ្នាក់ក្រោមជាតិចូលរួមការអនុវត្ត **ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជ នៅក្នុងដែនរាជធានី-ខេត្តសាមី។

### ១.១.៤- អ្នកផលិតគ្រាប់ពូជ

**ផលិតករគ្រាប់ពូជ** សំដៅដល់បុគ្គល ក្រុម ក្រុមហ៊ុន សហគមន៍កសិកម្ម សមាគម ឬ អង្គការក្រៅរដ្ឋាភិបាល ដែលផលិត និងធ្វើអាជីវកម្មគ្រាប់ពូជ នៅក្នុងដែនរាជធានី-ខេត្តសាមី។

## ១.២- តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការអនុវត្ត ប.គ.ព

### ១.២.១- នាយកដ្ឋានពូជដំណាំ

ក្នុងក្របខណ្ឌអនុវត្ត**ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ **នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម មានភារកិច្ចដូចខាងក្រោម៖

- អប់រំនិងផ្សព្វផ្សាយអំពីរចនាសម្ព័ន្ធនិងនីតិវិធីនៃការអនុវត្ត **ប.គ.ព** ដល់អ្នកពាក់ព័ន្ធនានាក្នុងវិស័យពូជដំណាំ
- ពិនិត្យរាល់ពាក្យស្នើសុំរបស់អ្នកផលិតគ្រាប់ពូជ ដើម្បីវាយតម្លៃមុនពេលអគ្គនាយកដ្ឋានកសិកម្មសម្រេចចិត្តផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ
- រៀបចំគោលការណ៍ណែនាំ និងបណ្តុះបណ្តាលស្តីពីបច្ចេកទេសត្រួតពិនិត្យគុណភាពតាម **ប.គ.ព** ដល់មន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទរាជធានី-ខេត្ត វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា

- គ្រប់គ្រងបញ្ជីអ្នកផលិតគ្រាប់ពូជស្របច្បាប់និងប្រភេទពូជស្រូវដែលបានស្នើសុំផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការនិងសម្របសម្រួលជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ក្នុងការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល និងការយកសំណាកគ្រាប់ពូជស្រូវដើម្បីវិភាគគុណភាពនៅមន្ទីរពីសោធន៍ វាយតម្លៃលទ្ធផលសម្រាប់អគ្គនាយកដ្ឋានកសិកម្មធ្វើសេចក្ដីសម្រេចចិត្តផ្ដល់ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.ព** ជូនអ្នកផលិតគ្រាប់ពូជ
- តាមដាននិងត្រួតពិនិត្យឃ្លាំងស្តុកនិងការធ្វើចរាចរណ៍គ្រាប់ពូជស្រូវលើទីផ្សារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រក្សាទុករាល់ឯកសារពាក់ព័ន្ធនិងរបាយការណ៍ត្រួតពិនិត្យទាំងអស់ ដើម្បីទុកជាឯកសារកាលប្បវត្តិ

### ១.២.២- នាយកដ្ឋានដំណាំស្រូវ

ក្នុងក្របខណ្ឌអនុវត្ត **ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ **នាយកដ្ឋានដំណាំស្រូវ** មានភារកិច្ចដូចខាងក្រោម៖

- បណ្ដុះបណ្ដាលស្ដីពីបច្ចេកទេសផលិតកម្មគ្រាប់ស្រូវតាម **ប.គ.ព** ដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

### ១.២.៣- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

ក្នុងក្របខណ្ឌអនុវត្ត **ប.គ.ព** សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** មានភារកិច្ចដូចខាងក្រោម៖

- ទទួលនិងបញ្ជូនរាល់ពាក្យស្នើសុំរបស់អ្នកផលិតគ្រាប់ពូជស្រូវទៅ**អគ្គនាយកដ្ឋានកសិកម្ម** សម្រាប់បន្តនីតិវិធី
- រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីបច្ចេកទេសត្រួតពិនិត្យគុណភាពតាម **ប.គ.ព** ដល់គណៈកម្មាធិការត្រួតពិនិត្យគុណភាពនៃអ្នកផលិតគ្រាប់ពូជ ដោយសហការជាមួយ**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម
- គ្រប់គ្រងបញ្ជីអ្នកផលិតគ្រាប់ពូជស្រូវស្របច្បាប់និងប្រភេទពូជស្រូវដែលបានស្នើសុំផលិត នៅក្នុងដែនរាជធានី-ខេត្តសាមី

- សហការជាមួយមន្ត្រីត្រួតពិនិត្យគុណភាពពី**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្មក្នុងការត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាល និងការយកសំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគគុណភាពនៅមន្ទីរពីសោធន៍
- តាមដាននិងត្រួតពិនិត្យឃ្លាំងស្តុកនិងការចរាចរគ្រាប់ពូជស្រូវលើទីផ្សារនៅក្នុងដែនរាជធានី-ខេត្តសាមី
- រក្សាទុករាល់ឯកសារថតចម្លងពាក់ព័ន្ធនិងរបាយការណ៍ត្រួតពិនិត្យទាំងអស់ ដើម្បីទុកជាឯកសារកាលប្បវត្តិ

### ១.២.៤- អ្នកផលិតគ្រាប់ពូជ

សម្រាប់ផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវតាម **ប.គ.ព** **អ្នកផលិតគ្រាប់ពូជ**ត្រូវមានឯកសារ និងភារកិច្ចដូចខាងក្រោម៖

- មានលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ដែលចេញដោយ**អគ្គនាយកដ្ឋានកសិកម្ម**
- បំពេញនិងបញ្ជូនទម្រង់ពាក្យស្នើសុំព្រមទាំងឯកសារពាក់ព័ន្ធដែលមានចែងក្នុងទម្រង់ពាក្យស្នើសុំទៅ**អគ្គនាយកដ្ឋានកសិកម្ម**ដោយផ្ទាល់ ឬតាមរយៈ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត**
- ធានានិងទទួលខុសត្រូវលើគុណភាពគ្រាប់ពូជស្រូវដែលបានផលិតនិងធ្វើអាជីវកម្ម
- ផលិតនិងធ្វើអាជីវកម្មគ្រាប់ពូជស្រូវស្របច្បាប់ ដែលមិនបង្កគ្រោះថ្នាក់ដោយសារជំងឺហាមឃាត់ទាំង៣(បី)ប្រភេទ និងការលាយឡំផ្សេងទៀត
- ចូលរួមនិងសហការជាមួយមន្ត្រីត្រួតពិនិត្យពី**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម និង**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ក្នុងការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលនិងការយកសំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគគុណភាពនៅមន្ទីរពិសោធន៍
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវតាម **ប.គ.ព** ដែលរៀបចំ និងផ្តល់សេវាកម្មដោយ**អគ្គនាយកដ្ឋានកសិកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត**
- អនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវដែលបានរៀបចំដោយអគ្គនាយកដ្ឋានកសិកម្ម
- មានសៀវភៅកំណត់ត្រាផលិតកម្មនិងអាជីវកម្មគ្រាប់ពូជស្រូវ ស្របតាមគម្រូសៀវភៅដែលកំណត់ដោយ**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម។

### ១.៣- ប្រភេទពូជស្រូវអនុញ្ញាតឱ្យផលិត

ប្រភេទពូជស្រូវដែលអនុញ្ញាតឱ្យផលិតតាម **ប.គ.ព** ជាប្រភេទពូជស្រូវដែលបានចុះបញ្ជីចូលក្នុងបញ្ជីប្រភេទពូជដំណាំរបស់ជាតិ និងមិនស្ថិតនៅក្នុងបញ្ជីប្រភេទពូជដំណាំដែលបង្កគ្រោះថ្នាក់ឡើយ។

### ១.៤- លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ

លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ (ដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី២) ជាលិខិតអនុញ្ញាតផ្លូវការដែលចេញដោយ**អគ្គនាយកដ្ឋានកសិកម្ម** បន្ទាប់ពីបានដាក់ពាក្យស្នើសុំ និងបំពេញទៅតាមលក្ខខណ្ឌតម្រូវ។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល៣(បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរឬការដកហូតដោយ**អគ្គនាយកដ្ឋានកសិកម្ម** មុនពេលផុតសុពលភាព។

អ្នកផលិតគ្រាប់ដែលចង់បន្តផលិតកម្មនិងធ្វើអាជីវកម្មពូជដំណាំ ត្រូវស្នើសុំលិខិតអនុញ្ញាតឡើងវិញក្នុងរយៈពេល៣(បី)ខែ មុនផុតសុពលភាព។

### ១.៥- ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

ផលិតកម្មគ្រាប់ពូជស្រូវតាម **ប.គ.ព** ត្រូវឆ្លងកាត់ការត្រួតពិនិត្យទីវាលយ៉ាងហោចណាស់ចំនួន២(ពីរ)ដងក្នុងអំឡុងរដូវកាលដាំដុះនីមួយៗ គឺលើកទី១នៅក្នុងដំណាក់កាលមុនពេលចេញផ្កា និងលើកទី២នៅក្នុងដំណាក់កាលដាក់ម្សៅ។ ការត្រួតពិនិត្យត្រូវធ្វើឡើងដោយចៃដន្យយ៉ាងតិចបំផុត**១០%**នៃផ្ទៃដីផលិតកម្មសរុបតាមប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗ។ ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលនីមួយៗត្រូវយកសំណាកទំហំ**១ម៉ែត្រ x ១ម៉ែត្រ** ចំនួន**១០(ដប់)សំណាក** ដែលត្រូវជ្រើសរើសដោយចៃដន្យ ដោយមន្ត្រីត្រួតពិនិត្យគុណភាព។ របាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាលត្រូវរៀបចំភ្លាមៗ និងបញ្ជូនមក**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្មសម្រាប់បន្តនីតិវិធី។

### ១.៦- ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ

មន្ត្រីត្រួតពិនិត្យគុណភាពត្រូវយកសំណាកដោយចៃដន្យយ៉ាងតិច១០%នៃបរិមាណគ្រាប់ពូជកែច្នៃរួចសរុប តាមប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗរបស់អ្នកផលិតគ្រាប់ពូជ។ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវបញ្ជូនសំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគគុណភាពទៅមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ **អគ្គនាយកដ្ឋានកសិកម្ម**។ លទ្ធផលវិភាគគុណភាពនៅមន្ទីរពិសោធន៍នឹងត្រូវបញ្ជូនមក**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម ដើម្បីបន្តនីតិវិធី។

### ១.៧-ការអនុម័តមុនផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.៣

ផ្អែកលើរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល និងលទ្ធផលវិភាគគុណភាពនៅមន្ទីរពិសោធន៍ **អគ្គនាយកដ្ឋានកសិកម្ម**នឹងសម្រេចចិត្តអនុញ្ញាតផ្តល់អនុសាសន៍កែតម្រូវ ឬបដិសេធផ្តល់ជូនស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** ដល់អ្នកផលិតគ្រាប់ពូជ។ **អគ្គនាយកដ្ឋានកសិកម្ម**នឹងជូនដំណឹងស្តីពីការសម្រេចចិត្តដល់អ្នកផលិតគ្រាប់ពូជក្នុងរយៈពេលមិនលើសពី**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានលទ្ធផលពីមន្ទីរពិសោធន៍។

### ១.៨-ការផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.៣

**អគ្គនាយកដ្ឋានកសិកម្ម**ផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** ជូន**អ្នកផលិតគ្រាប់ពូជ** ដោយផ្អែកទៅលើបរិមាណគ្រាប់ពូជស្រូវសរុបដែលបានស្នើសុំនៅក្នុងទម្រង់(ខ)។ ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** ដែលភ្ជាប់ទៅនឹងបាវវេចខ្ចប់គ្រាប់ពូជស្រូវសម្រាប់លក់ គឺអនុញ្ញាតឱ្យប្រើប្រាស់បានតែ១(មួយ)ដង។

### ១.៩-កម្រៃសេវាកម្ម

ការចំណាយលើការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ និងការវិភាគគុណភាពនៅមន្ទីរពិសោធន៍ត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។ ដោយឡែក ការចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល ការចុះយកសំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគគុណភាព និងស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** ត្រូវកំណត់ដោយ**អគ្គនាយកដ្ឋានកសិកម្ម**។ រាល់ការចំណាយតាមប្រភេទប្រតិបត្តិការនីមួយៗខាងលើគឺជាបន្ទុករបស់**អ្នក ផលិតគ្រាប់ពូជ**។

## ផ្នែកទី២៖ នីតិវិធីអនុវត្ត ប.គ.៣

### ២.១- ការដាក់ពាក្យស្នើសុំ

២.១.១- អ្នកដាក់ពាក្យស្នើសុំផលិតនិងធ្វើអាជីវកម្មគ្រាប់ពូជស្រូវតាម **ប.គ.៣** ត្រូវមានផ្ទៃដីអប្បបរមាសម្រាប់ផលិតកម្មតាមប្រភេទពូជ និងថ្នាក់គ្រាប់ពូជនីមួយៗ ដូចខាងក្រោម៖

| **ថ្នាក់គ្រាប់ពូជ** | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
|---|---|---|---|
| **ផ្ទៃដីផលិតកម្មសម្រាប់ប្រភេទពូជនីមួយៗ** | ០,២០ ហ.ត | ០,៥០ ហ.ត | ៥,០០ ហ.ត |

២.១.២- អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញទម្រង់ពាក្យស្នើសុំសម្រាប់លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ ដូចមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី១** និងដាក់ជូន**អគ្គនាយកដ្ឋានកសិកម្ម**ឱ្យបានយ៉ាងតិច**៣(បី)ខែ** មុនកាលបរិច្ឆេទចាប់ផ្តើមផលិតកម្មគ្រាប់ពូជស្រូវរបស់ខ្លួន។

២.១.៣- អ្នកដាក់ពាក្យស្នើសុំអាចដាក់សំណើដោយផ្ទាល់នៅ**អគ្គនាយកដ្ឋានកសិកម្ម** ឬនៅ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត**ដែលខ្លួននឹងផលិតគ្រាប់ពូជស្រូវ។ ការបញ្ជូនឯកសារច្បាប់ដើមមក**អគ្គនាយកដ្ឋានកសិកម្ម** និងការបញ្ជូនឯកសារច្បាប់ចម្លងទៅ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត**ពាក់ព័ន្ធត្រូវធ្វើឡើងក្នុងរយៈពេល**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ**បន្ទាប់ពីបានទទួលពាក្យស្នើសុំ។

២.១.៤- **អគ្គនាយកដ្ឋានកសិកម្ម**ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំដោយផ្ទាល់ ឬតាមរយៈ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** អំពីលទ្ធផលនៃសេចក្តីសម្រេចចិត្តក្នុងរយៈពេល**២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានពាក្យស្នើសុំ។ **អគ្គនាយកដ្ឋានកសិកម្ម**នឹងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ(ដូចមានភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី២**)ដែលមានសុពលភាពរយៈពេល៣(បី)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាតនេះ នៅពេលដែលអ្នកដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌតម្រូវ លើកលែងតែមានការព្យួរ ឬការដកហូតមុនកាលបរិច្ឆេទផុតសុពលភាព ដោយសារការរំលោភបំពានធ្ងន់ធ្ងរនៃអ្នកផលិតគ្រាប់ពូជ។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌតម្រូវ **អគ្គនាយកដ្ឋានកសិកម្ម**ត្រូវជូនដំណឹងអំពីការកែតម្រូវដើម្បីបន្ត ឬបញ្ចប់ទាំងស្រុងនូវនីតិវិធី។

### ២.២- ហេតុផលនៃការបដិសេធ

**អគ្គនាយកដ្ឋានកសិកម្ម**អាចបដិសេធការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំដល់អ្នកស្នើសុំដោយផ្អែកលើមូលដ្ឋានមួយឬច្រើនដូចខាងក្រោម៖

- មិនមានភស្តុតាងបញ្ជាក់អំពីជំនាញនិងបទពិសោធន៍នៅក្នុងផលិតកម្មគ្រាប់ពូជស្រូវ(ឧទាហរណ៍៖ មិនបានជូនភ្ជាប់វិញ្ញាបនបត្របញ្ជាក់អំពីវគ្គបណ្តុះបណ្តាល កិច្ចសន្យាផលិតកម្មគ្រាប់ពូជកន្លងមក។ល។)
- ព័ត៌មានមិនពេញលេញ ឬមិនពិតនៅក្នុងខ្លឹមសារនៃការដាក់ពាក្យស្នើសុំ។

## ២.៣- សិទ្ធិក្នុងការប្តឹងជំទាស់

អ្នកដាក់ពាក្យស្នើសុំអាចប្តឹងជំទាស់នឹងការបដិសេធរបស់**អគ្គនាយកដ្ឋានកសិកម្ម** ប្រសិនមានភស្តុតាងបញ្ជាក់ថាខ្លួនបានបំពេញគ្រប់តាមលក្ខខណ្ឌតម្រូវ។ **អគ្គនាយកដ្ឋានកសិកម្ម**ទុករយៈពេល**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីចេញលិខិតបដិសេធផ្លូវការសម្រាប់អ្នកដាក់ពាក្យស្នើសុំក្នុងការប្តឹងជំទាស់។

## ២.៤- សេចក្តីប្រកាសអំពីផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ

អ្នកផលិតគ្រាប់ពូជត្រូវបំពេញទម្រង់(ក)៖ **ផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ** (ដូចមានជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៣**) ដើម្បីផ្ញើជូន**អគ្គនាយកដ្ឋានកសិកម្ម**ដោយផ្ទាល់ ឬតាមរយៈ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ឱ្យបានយ៉ាងតិច**២០(ម្ភៃ)ថ្ងៃ** មុនពេលចាប់ផ្តើមដាំដុះ។ ឯកសារច្បាប់ដើមត្រូវបញ្ជូនមក**អគ្គនាយកដ្ឋានកសិកម្ម** ហើយឯកសារច្បាប់ចម្លងត្រូវបញ្ជូនមក**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ក្នុងរយៈពេល**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីបានទទួលទម្រង់(ក)។

## ២.៥- ការកំណត់ស្រែសម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

មន្ត្រីត្រួតពិនិត្យគុណភាពនៃ**នាយកដ្ឋានពូជដំណាំ** ឬ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ត្រូវជ្រើសរើសស្រែសម្រាប់ត្រួតពិនិត្យគុណភាពផលិតកម្មទីវាលដោយចៃដន្យ ដោយយកយ៉ាងតិចបំផុត**១០%**នៃផ្ទៃដីផលិតកម្មសរុបតាមប្រភេទពូជនិងចំណាត់ថ្នាក់គ្រាប់ពូជនីមួយៗរបស់ផលិតករគ្រាប់ពូជស្រូវ។

## ២.៦- ការផ្ទៀងផ្ទាត់ប្រភពគ្រាប់ពូជសម្រាប់ផលិតកម្មគ្រាប់ពូជ

មន្ត្រីត្រួតពិនិត្យគុណភាពនៃ**នាយកដ្ឋានពូជដំណាំ** ឬ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត**ត្រូវផ្ទៀងផ្ទាត់ប្រភពដើមនៃថ្នាក់គ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជពូជចុះបញ្ជី នៅពេលត្រួតពិនិត្យគុណភាពផលិតកម្មនៅទីវាលលើកទីមួយ ដើម្បីបញ្ជាក់ថាថ្នាក់គ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជីត្រូវបានទិញពីអង្គភាព/គ្រឹះស្ថានស្របច្បាប់ណាមួយ ដោយពិនិត្យទៅលើស្លាកសញ្ញា វិក្កយបត្រលក់ និងសំបកវេចខ្ចប់។ ក្នុងករណីរកឃើញថាថ្នាក់គ្រាប់ពូជគ្រឹះ ឬគ្រាប់ពូជចុះបញ្ជីមិនមានប្រភពដើមច្បាស់លាស់ត្រូវបដិសេធផលិតកម្មរបស់អ្នកផលិតគ្រាប់ពូជតែម្តង។

## ២.៧- ការត្រួតពិនិត្យស្រែផលិតកម្មគ្រាប់ពូជស្រូវ

**២.៧.១-** ស្រែផលិតកម្មគ្រាប់ពូជស្រូវដែលបានបញ្ជាក់នៅក្នុងទម្រង់(ក)នឹងត្រូវត្រួតពិនិត្យយ៉ាងហោចណាស់២(ពីរ)ដងក្នុងអំឡុងរដូវកាលដាំដុះ ដោយលើកទី១នៅដំណាក់កាលមុនចេញផ្កា និងលើកទី២ នៅដំណាក់កាលដាក់ម្សៅ។ មន្ត្រីត្រួតពិនិត្យគុណភាពនៃ**នាយកដ្ឋានពូជដំណាំ** ឬ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត**ត្រូវជូនដំណឹងដល់អ្នកផលិតគ្រាប់ពូជស្រូវ យ៉ាងហោចណាស់**២៤(ម្ភៃបួន)ម៉ោង** មុនពេលចុះត្រួតពិនិត្យ។

**២.៧.២-** មន្ត្រីត្រួតពិនិត្យគុណភាពត្រូវពិនិត្យស្រែផលិតកម្មគ្រាប់ពូជដែលបានជ្រើសរើសតាមគោលការណ៍បច្ចេកទេសនៃ **ប.គ.៣** រួចសរសេររបាយការណ៍ត្រួតពិនិត្យ (ដូចជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៤**) ដោយត្រូវបង្ហាញអំពីលទ្ធផលត្រួតពិនិត្យ កំណត់សំគាល់ សន្និដ្ឋាន និងអនុសាសន៍ ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ដល់អ្នកផលិតគ្រាប់ពូជ ឬតំណាង។ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវផ្តល់របាយការណ៍ត្រួតពិនិត្យដែលមានចុះហត្ថលេខាចំនួន**១(មួយ)ច្បាប់** ដល់**អ្នកផលិតគ្រាប់ពូជ**ឬតំណាង **១(មួយ)ច្បាប់**ដល់**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម និង**១(មួយ)ច្បាប់**ទៀតដល់**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត**។

**២.៧.៣-** ក្នុងករណីការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២ស្របតាមស្តង់ដារ **អ្នកផលិតគ្រាប់ពូជ** អាចបន្តនីតិវិធីស្នើសុំទម្រង់(ខ)៖ **សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ** (ជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៥**) ដោយផ្ទាល់ដល់**អគ្គនាយកដ្ឋានកសិកម្ម** ឬតាមរយៈ**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត**។

**២.៧.៤-** ប្រសិនបើគុណភាពមិនស្របតាមស្តង់ដារទីវាលដែលមិនអាចកែលម្អបាន **អគ្គនាយកដ្ឋានកសិកម្ម**នឹងចេញលិខិតបដិសេធជាផ្លូវការចំពោះស្រែផលិតកម្មគ្រាប់ពូជស្រូវទាំងអស់ ជូន**អ្នកផលិតគ្រាប់ពូជ** ក្នុងរយៈពេល**៣(បី)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីការត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២រួច។

**២.៧.៥-** ប្រសិនបើគុណភាពមិនស្របតាមស្តង់ដារទីវាល ប៉ុន្តែអាចកែលម្អបាន មន្ត្រីត្រួតពិនិត្យគុណភាពត្រូវផ្តល់អនុសាសន៍និងបញ្ចូលទៅក្នុងរបាយការណ៍ត្រួតពិនិត្យ ព្រមទាំងកំណត់កាលបរិច្ឆេទចុះត្រួតពិនិត្យឡើងវិញ(ត្រួតពិនិត្យលើកទី៣) ជាមួយអ្នកផលិតគ្រាប់ពូជ។ ប្រសិនបើ**អ្នកផលិតគ្រាប់ពូជ**នៅតែមិនអនុវត្តតាមអនុសាសន៍ដែលបានកំណត់ក្នុងរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាលលើកទី២ **អគ្គនាយកដ្ឋានកសិកម្ម**នឹងចេញលិខិតបដិសេធជាផ្លូវការចំពោះស្រែផលិតកម្មគ្រាប់ពូជស្រូវទាំងអស់ដល់អ្នកផលិតគ្រាប់ពូជក្នុងរយៈពេល**៣(បី)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីការត្រួតពិនិត្យឡើងវិញ(ត្រួតពិនិត្យលើកទី៣)រួច។

## ២.៨- ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ

២.៨.១- **អគ្គនាយកដ្ឋានកសិកម្ម**ផ្តល់សិទ្ធិដល់**អ្នកផលិតគ្រាប់ពូជ**ក្នុងការសម្រេចចិត្តជ្រើសរើសលក្ខខណ្ឌនៃការយកសំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគ ដែលមានចែងក្នុងទម្រង់(ខ)៖ **សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ**(ដូចជូនភ្ជាប់ក្នុង**ឧបសម្ព័ន្ធទី៥**)។ អ្នកផលិតគ្រាប់ពូជអាចសម្រេចចិត្តជ្រើសរើសលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌ២(ពីរ)ដូចខាងក្រោម៖

- **អ្នកផលិតគ្រាប់ពូជ**អាចស្នើសុំវិភាគគុណភាពគ្រាប់ពូជតែ១០%នៃឡូត៍គ្រាប់ពូជស្រូវសរុបនៃប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗ ដោយចៃដន្យសម្រាប់វាយតម្លៃគុណភាពគ្រាប់ពូជទាំងអស់។ លក្ខខណ្ឌនេះមានន័យថា សំណាកគ្រាប់ពូជស្រូវសម្រាប់វិភាគគុណភាពដែលត្រូវជ្រើសរើសដោយចៃដន្យ គឺតំណាងឱ្យឡូត៍គ្រាប់ពូជសរុបនៃប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗ។

- **អ្នកផលិតគ្រាប់ពូជ**អាចស្នើសុំវិភាគគ្រាប់ពូជស្រូវគ្រប់ឡូត៍នៃប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗសម្រាប់វិភាគគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍។ លក្ខខណ្ឌនេះមានន័យថា **អគ្គនាយកដ្ឋានកសិកម្ម**នឹងផ្តល់ជូនស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** ចំពោះឡូត៍គ្រាប់ពូជណាដែលស្របតាមស្តង់ដារគ្រាប់ពូជស្រូវតែប៉ុណ្ណោះ(សូមមើល **ផ្នែកទី៥**)។

**២.៨.២-** ក្រោយពេលបញ្ចប់ការកែច្នៃនិងវេចខ្ចប់គ្រាប់ពូជ **អ្នកផលិតគ្រាប់ពូជ**ត្រូវបំពេញនិងចុះហត្ថលេខាលើទម្រង់(ខ) ហើយបញ្ជូនទៅ**អគ្គនាយកដ្ឋានកសិកម្ម**ដោយផ្ទាល់ ឬ**តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត**។ ឯកសារច្បាប់ដើមត្រូវបញ្ជូនមក**អគ្គនាយកដ្ឋានកសិកម្ម** ហើយឯកសារច្បាប់ចម្លងត្រូវបញ្ជូនមក**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ក្នុងរយៈពេល**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ**បន្ទាប់ពីបានទទួលទម្រង់(ខ)។

**២.៨.៣-** ក្នុងករណីទីតាំងឃ្លាំងរបស់អ្នកផលិតគ្រាប់ពូជ នៅរាជធានីភ្នំពេញ **អ្នកផលិតគ្រាប់ពូជ**អាចដាក់ទម្រង់(ខ)ដោយផ្ទាល់នៅ**អគ្គនាយកដ្ឋានកសិកម្ម**។

**២.៨.៤- អគ្គនាយកដ្ឋានកសិកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត** ត្រូវជូនដំណឹងដល់**អ្នកផលិតគ្រាប់ពូជ**យ៉ាងហោចណាស់**២៤(ម្ភៃបួន)ម៉ោង**មុនចុះយកសំណាកសម្រាប់ត្រួតពិនិត្យគុណភាពគ្រាប់ពូជនៅមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ទទួលស្គាល់ដោយ**អគ្គនាយកដ្ឋានកសិកម្ម**។ ក្នុងពេលត្រួតពិនិត្យ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវផ្ទៀងផ្ទាត់ព័ត៌មានដែលបានផ្តល់នៅក្នុងទម្រង់(ខ)និងត្រូវយកសំណាកដោយចៃដន្យយ៉ាងតិចបំផុត១០%នៃឡូត៍គ្រាប់ពូជសរុបតាមប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗ ដោយអនុលោមតាមវិធានរបស់អ៊ីសតា(ISTA) (សូមមើល **ផ្នែកទី៤**)។ ក្នុងករណីឡូត៍គ្រាប់ពូជបានជ្រើសរើសមានបរិមាណគ្រាប់ពូជស្រូវសម្រេចលើសពី**១០(ដប់)តោន** ឡូត៍គ្រាប់ពូជនោះនឹងត្រូវបំបែកជាឡូត៍ថ្មី ដែលទំហំឡូត៍នីមួយៗត្រូវមានបរិមាណមិនលើសពី**១០(ដប់)តោន**។

## ២.៩- ការវិភាគគុណភាពគ្រាប់ពូជ

មន្ត្រីវិភាគគុណភាពគ្រាប់ពូជត្រូវបែងចែកសំណាកដោយអនុលោមតាមវិធានរបស់អ៊ីសតា(ISTA) ហើយត្រូវវិភាគគុណភាពដូចជា គ្រាប់ពូជសុទ្ធ គ្រាប់ស្មៅ គ្រាប់ដំណាំដទៃ គ្រាប់ពូជស្រូវផ្សេង គ្រាប់ស្រូវក្រហម ដំណុះគ្រាប់ពូជ សំណើមគ្រាប់ពូជ និងកម្ទេចកម្ទីផ្សេងៗ។ លទ្ធផលនៃការវិភាគគុណភាពនឹងត្រូវបញ្ជូនទៅ**នាយកដ្ឋានពូជដំណាំ** ដើម្បីធ្វើរបាយការណ៍ជូន**អគ្គនាយកដ្ឋានកសិកម្ម**ពិនិត្យនិងសម្រេចក្នុងរយៈពេល**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានលទ្ធផល។

## ២.១០-សេចក្តីសម្រេចចុងក្រោយ

**អគ្គនាយកដ្ឋានកសិកម្ម**នឹងសម្រេចចិត្តទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

២.១០.១- ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** នឹងត្រូវផ្តល់ជូន**អ្នកផលិតគ្រាប់ពូជ** អំឡុងពេល**៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីទទួលបានលទ្ធផលនៃការវិភាគគុណភាពសំណាកគ្រាប់ពូជស្រូវតាមប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗ បង្ហាញថាស្របតាមស្តង់ដារគ្រាប់ពូជស្រូវ។

២.១០.២- ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** នឹងមិនត្រូវផ្តល់ជូន**អ្នកផលិតគ្រាប់ពូជ** ក្នុងករណី លទ្ធផលវិភាគគុណភាពសំណាកគ្រាប់ពូជស្រូវតាមប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗ មិនស្របតាមស្តង់ដារគ្រាប់ពូជស្រូវ។ ប្រសិនបើលទ្ធផលនៃការវិភាគគ្រាប់ពូជមិនស្របតាមស្តង់ដារលើចំណុច៖ កម្មេចកម្ទីរ គ្រាប់ស្មៅ សំណើម និងអត្រាដំណុះ (ក្នុងករណីដំណេកគ្រាប់ពូជមិនលើសពី២ខែ) **អ្នកផលិតគ្រាប់ពូជ** អាចកែលម្អលើចំណុចខាងលើ ហើយត្រូវដាក់ទម្រង់(**ខ**)ជាថ្មី ដើម្បីវិភាគគុណភាពគ្រាប់ពូជសាឡើងវិញ។ **អគ្គនាយកដ្ឋានកសិកម្ម**នឹងមិនផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.៣** ប្រសិនបើលទ្ធផលវិភាគគុណភាពដែលបានអនុញ្ញាតនៅតែមិនស្របតាមស្តង់ដារគ្រាប់ពូជស្រូវ។

# ផ្នែកទី៣៖ លក្ខណៈវិនិច្ឆ័យសម្រាប់ការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

## ៣.១- លក្ខខណ្ឌតម្រូវសម្រាប់ស្រែផលិតកម្មគ្រាប់ពូជ

ស្រែសម្រាប់ផលិតកម្មគ្រាប់ពូជស្រូវមិនត្រូវមានស្រូវដុះមួរឬដុះសាឡើយ។ ដីស្រែផលិតគ្រាប់ពូជស្រូវតាម **ប.គ.៣** ត្រូវតែជាដីស្រែធ្លាប់ដាំដំណាំប្រភេទគ្រាប់តូចផ្សេងៗ ឬធ្លាប់បានដាំដុះពូជស្រូវតែមួយដូចពូជស្រូវដែលត្រូវអនុវត្តតាម **ប.គ.៣** ក្នុងរយៈពេលយ៉ាងហោចណាស់**១(មួយ)រដូវ** ដោយគោរពទៅតាមគោលការណ៍ណែនាំបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវតាម **ប.គ.៣** ។

## ៣.២- គម្លាតស្រែផលិតកម្មគ្រាប់ពូជ

ស្រែផលិតកម្មគ្រាប់ពូជស្រូវត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកពីស្រែផលិតកម្មស្រូវដទៃផ្សេងទៀតដែលមានចម្ងាយប្រមាណ**១(មួយ)ម៉ែត្រ** ឬត្រូវមានរបាំងទីតាំង (ចង្អូរទឹក របងឈើរស់តូចៗ របងខណ្ឌជាដើម។ល។) ដើម្បីទប់ស្កាត់ការលាយឡំដោយសារការបម្លាស់ទីនៃគ្រឿងយន្តនិងកត្តាផ្សេងៗ។

## ៣.៣- ប្រភេទពូជលាយ

ចំនួនប្រភេទពូជស្រូវផ្សេងអនុញ្ញាតឱ្យមានក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវច្រើនបំផុត គឺ៖

| **ថ្នាក់ផលិតកម្មគ្រាប់ពូជ** | **មុនដំណាក់កាលចេញផ្កា**<br>**ចំនួនដើម/១០ម^២** | **ដំណាក់កាលដាក់ម្សៅ**<br>**ចំនួនកួរ/១០ម^២** |
|---|---|---|
| គ្រាប់ពូជចុះបញ្ជី | ១ | ១ |
| គ្រាប់ពូជវិញ្ញាបនបត្រ | ៣ | ៣ |

## ៣.៤- ប្រភេទស្មៅហាមឃាត់

ប្រភេទស្មៅហាមឃាត់ទាំងនោះរួមមាន៖ ប្រភេទស្មៅបែកក្បាល (*Echinochloa* spp.) ស្មៅកន្ទុយក្ងោក (*Leptochloa chinensis*) និងកក់ធ័ត្រធំ (*Cyperus iria*)។

ចំនួនស្មៅហាមឃាត់អនុញ្ញាតឱ្យមាននៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវច្រើនបំផុត គឺ៖

| **ថ្នាក់ផលិតកម្មគ្រាប់ពូជ** | **មុនដំណាក់កាលចេញផ្កា**<br>**ចំនួនដើម/១០ម^២** | **ដំណាក់កាលដាក់ម្សៅ**<br>**ចំនួនកួរ/១០ម^២** |
|---|---|---|
| គ្រាប់ពូជចុះបញ្ជី | ៥ | ៥ |
| គ្រាប់ពូជវិញ្ញាបនបត្រ | ១០ | ១០ |

### ៣.៥- ប្រភេទជំងឺហាមឃាត់

ជំងឺហាមឃាត់៣(បី)ប្រភេទ រួមមាន៖ ជំងឺប្លាស់ អុចត្នោត និងរលាកស្រទបស្លឹកត្រូវបានកំណត់ជាជំងឺហាមឃាត់។ ប្រសិនបើ គុម្ពស្រូវនីមួយៗកើតជំងឺចាប់ពី**២៥%**ឡើងទៅទើបគិតជាគុម្ពស្រូវរងការបំផ្លាញ។ ចំនួនគុម្ពស្រូវរងការបំផ្លាញដោយជំងឺនៅក្នុងផលិតកម្មគ្រាប់ពូជមិនត្រូវឱ្យមានលើសពី**៥០%**ទេនៅក្នុងដំណាក់កាលស្រូវទុំ។ ប្រសិនបើ គុម្ពស្រូវរងការបំផ្លាញដោយជំងឺហាមឃាត់រកឃើញលើសពីស្តង់ដារកំណត់ **ផលិតករគ្រាប់ពូជស្រូវ**មិនត្រូវបានអនុញ្ញាតឱ្យប្រមូលទុកជាគ្រាប់ពូជទេ។ ការណែនាំសម្រាប់ការវាយតម្លៃលម្អិតនៃជំងឺហាមឃាត់ទាំង៣(បី)ប្រភេទត្រូវបានកំណត់នៅក្នុងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការត្រួតពិនិត្យគុណភាពតាម **ប.គ.៣**។

### ៣.៦- ដំណើរការត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

**៣.៦.១-** មុនចុះត្រួតពិនិត្យគុណភាពផលិតកម្មទីវាល មន្ត្រីត្រួតពិនិត្យគុណភាពត្រូវសួរបញ្ជាក់ជាមួយ **អ្នកផលិតគ្រាប់ពូជ** អំពីទីតាំងជាក់ស្តែង ប្រភេទពូជត្រូវត្រួតពិនិត្យ និងប្រវត្តិនៃការដាំដុះពីមុននៃស្រែផលិតកម្មគ្រាប់ពូជ។

**៣.៦.២-** នៅពេលត្រួតពិនិត្យស្រែ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវផ្ទៀងផ្ទាត់ចរិតលក្ខណៈប្រភេទពូជស្រូវក្នុងស្រែផលិតកម្មគ្រាប់ពូជ ទៅនឹងចរិកលក្ខណៈជាទូទៅរបស់ប្រភេទពូជស្រូវដែលស្នើសុំផលិត រួចពិនិត្យមើលព្រំប្រទល់ និងគម្លាតស្រែផលិតកម្មគ្រាប់ពូជស្របតាមលក្ខខណ្ឌតម្រូវនៃ **ប.គ.៣**។ បន្ទាប់មកមន្ត្រីត្រួតពិនិត្យគុណភាពត្រូវចុះពិនិត្យសំណាកលើផ្ទៃដីទំហំ **១ម៉ែត្រ x ១ម៉ែត្រ** និងត្រូវជ្រើសរើសចំនួន**១០(ដប់)** សំណាកដោយចៃដន្យក្នុងស្រែផលិតកម្មគ្រាប់ពូជតាមនីតិវិធីដែលបានកំណត់ក្នុងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការត្រួតពិនិត្យគុណភាពតាម **ប.គ.៣**។

**៣.៦.៣-** មន្ត្រីត្រួតពិនិត្យគុណភាពត្រូវពិនិត្យនិងរាប់ចំនួនដើមស្រូវប្រភេទពូជលាយ ចំនួនដើមស្មៅហាមឃាត់ និងដើមស្រូវមានជំងឺហាមឃាត់ក្នុងសំណាកដែលបានជ្រើសរើសសម្រាប់ត្រួតពិនិត្យនៅក្នុងដំណាក់កាលបែកគុម្ព និងដំណាក់កាលដាក់ម្សៅ។ ក្នុងករណីស្រែផលិតកម្មគ្រាប់ពូជស្រូវមិនឆ្លើយតបតាមស្តង់ដាកំណត់ មន្ត្រីត្រួតពិនិត្យគុណភាពត្រូវណែនាំម្ចាស់ស្រែឱ្យកែលម្អ និងបន្តត្រួតពិនិត្យឡើងវិញប្រសិនបើមានឱកាសត្រួតពិនិត្យម្តងទៀត ឬត្រូវបានបដិសេធក្នុងករណីលទ្ធផលត្រួតពិនិត្យគុណភាពផលិតកម្មទីវាលចុងក្រោយនៃស្រែនោះនៅតែមិនឆ្លើយតបទៅនឹងស្តង់ដារទីវាល។

**៣.៦.៤-** បន្ទាប់ពីត្រួតពិនិត្យគុណភាពផលិតកម្មទីវាលរួច មន្ត្រីត្រួតពិនិត្យគុណភាពត្រូវបំពេញរបាយការណ៍ដោយបង្ហាញលទ្ធផលជាក់ស្តែង និងផ្តល់អនុសាសន៍អនុវត្តបន្តក្នុងករណីអាចមានលទ្ធភាពកែលម្អបានឱ្យស្របទៅតាមស្តង់ដារទីវាល(សូមមើល**ចំណុច២.៧**)។ មន្ត្រីត្រួតពិនិត្យនិង**អ្នកផលិតគ្រាប់ពូជ** ឬ តំណាងចាំបាច់ត្រូវចុះហត្ថលេខាលើរបាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល។

## ផ្នែកទី៤៖ ការយកសំណាកគ្រាប់ពូជនៅក្នុងឃ្លាំងសម្រាប់វិភាគគុណភាព

ការយកសំណាកគ្រាប់ពូជនៃឡូត៍គ្រាប់ពូជទៅតាមប្រភេទពូជនិងថ្នាក់គ្រាប់ពូជនីមួយៗត្រូវអនុវត្តទៅតាមវិធានអុីសតា( ISTA ) ឆ្នាំ២០១៨។

### ៤.១- ឡូត៍គ្រាប់ពូជ និងការរៀបចំគ្រាប់ពូជក្នុងឃ្លាំង

**៤.១.១-** បរិមាណអតិបរមានៃឡូត៍គ្រាប់ពូជមួយនៃប្រភេទពូជស្រូវនីមួយៗ គឺ **១០ 000**គីឡូក្រាម។

**៤.១.២-** ឡូត៍គ្រាប់ពូជស្រូវត្រូវបានរៀបចំឱ្យមានរបៀបរៀបរយ និងងាយស្រួលយកសំណាកពីគ្រប់ផ្នែកទាំងអស់នៃឡូត៍។ ឡូត៍គ្រាប់ពូជស្រូវត្រូវមានកូដ ឬលេខសម្គាល់ដោយឡែកៗពីគ្នា ដែលកំណត់ដោយ**អ្នកផលិតករគ្រាប់ពូជស្រូវ**។

### ៤.២- ការរៀបចំសំណាកសម្រាប់វិភាគ

ការយកសំណាកធ្វើឡើងដោយចៃដន្យ និងទៅតាមលំដាប់លំដោយដូចខាងក្រោម៖

#### ៤.២.១- សំណាកបឋម

សំណាកបឋមយកចេញពីបាវនីមួយៗដែលបានជ្រើសរើសដោយចៃដន្យ និងត្រូវមានបរិមាណប្រហាក់ប្រហែលគ្នា។ សំណាកបឋមត្រូវយកចេញពីផ្នែកខាងលើ ផ្នែកកណ្តាល និងផ្នែកខាងក្រោមនៃបាវក្នុងករណីចំនួនបាវមានចន្លោះពី១ទៅ១៥បាវ។ ប្រសិនបើ ចំនួនបាវលើសពី១៥បាវ មិនចាំបាច់យកសំណាកបឋមពី៣ទីតាំងក្នុងបាវតែមួយនោះទេ ប៉ុន្តែអាចយកចេញពី៣ទីតាំងផ្សេងគ្នានៃពំនូកបាវស្រូវ។

ចំនួនសំណាកបឋមដែលត្រូវការ គឺអាស្រ័យទៅនឹងចំនួនបាវវេចខ្ចប់គ្រាប់ពូជនៃឡូត៍គ្រាប់ពូជ ដែលបង្ហាញក្នុងតារាងខាងក្រោម៖

| ចំនួនបាវ | ចំនួនអប្បបរមានៃសំណាកបឋម |
|---|---|
| ១ – ៤ | សំណាកបឋមចំនួន៣ពីបាវនីមួយៗ |
| ៥ – ៨ | សំណាកបឋមចំនួន២ពីបាវនីមួយៗ |
| ៩ – ១៥ | សំណាកបឋមចំនួន១ពីបាវនីមួយៗ |
| ១៦ – ៣០ | សំណាកបឋមចំនួន១៥យកចេញពី១៥បាវផ្សេងគ្នា ដែល១បាវយក១សំណាក |
| ៣១ – ៥៩ | សំណាកបឋមចំនួន២០យកចេញពី២០បាវផ្សេងគ្នា ដែល១បាវយក១សំណាក |
| > ៦០ | សំណាកបឋមចំនួន៣០យកចេញពី៣០បាវផ្សេងគ្នា ដែល១បាវយក១សំណាក |

#### ៤.២.២- សំណាករួម

សំណាកបឋមត្រូវបានដាក់បញ្ចូលគ្នានិងច្របល់ឱ្យសព្វដើម្បីបង្កើតជាសំណាករួម។

### ៤.២.៣- សំណាកបញ្ជូន

សំណាកបញ្ជូនផ្ញើទៅមន្ទីរពិសោធន៍ត្រូវមានទម្ងន់អប្បបរមា៧០០ក្រាម។ ប្រសិនបើសំណាករួមមានបរិមាណជិត៧០០ក្រាម ត្រូវបញ្ជូនទៅមន្ទីរពិសោធន៍ទាំងអស់តែម្តង។ ប្រសិនបើសំណាករួមមានបរិមាណច្រើន នោះត្រូវបែងចែកដោយប្រើវិធីរំលែកដោយដៃពាក់កណ្តាលស្មើគ្នា។ សំណាកត្រូវបែងចែកជាបីចំណែកសម្រាប់ផ្ទៀងផ្ទាត់គ្នា ដោយមួយចំណែករក្សាទុកនៅអ្នកផលិតគ្រាប់ពូជ មួយចំណែករក្សាទុកនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងមួយចំណែកទៀតបញ្ជូនទៅមន្ទីរពិសោធន៍។

- **វិធីរំលែកដោយដៃពាក់កណ្តាលស្មើគ្នា**

ចាក់សំណាករួមជាពំនូកនៅលើផ្ទៃស្អាតមួយ រួចចែកពំនូកនោះជាពីរចំណែកស្មើគ្នា ដោយចែកចំណែកនីមួយៗម្តងទៀតជា២(ពីរ)ដើម្បីឱ្យបាន៤(បួន)ចំណែក។ បន្ទាប់មកដាក់បញ្ចូលចំណែកដែលឈមគ្នា ដើម្បីទទួលបាន២(ពីរ)ពំនូកស្មើគ្នានិងមានលក្ខណៈប្រហាក់ប្រហែលគ្នា។ អនុវត្តវិធីបែបនេះបន្តទៀតបើចាំបាច់ ដើម្បីទទួលបានបរិមាណ៧០០ក្រាមសម្រាប់បញ្ជូនទៅមន្ទីរពិសោធន៍។

- **ការវេចខ្ចប់ និងការបិទស្លាកលើសំណាកបញ្ជូន**

សំណាកបញ្ជូនត្រូវវេចខ្ចប់ក្នុងថង់ស្អាត ដែលមានព័ត៌មានមូលដ្ឋាន ដូចជា៖ លេខសម្គាល់ឡូតិ៍គ្រាប់ពូជនៃផលិតករគ្រាប់ពូជស្រូវ ឈ្មោះពូជ ថ្នាក់គ្រាប់ពូជ និងអាសយដ្ឋានអ្នកផលិតគ្រាប់ពូជ។

### ៤.២.៤- សំណាកវិភាគ

នៅមន្ទីរពិសោធន៍ វិធីរំលែកដោយដៃពាក់កណ្តាលស្មើគ្នាត្រូវបានប្រើដើម្បីទទួលបានទម្ងន់អប្បបរមា៥០០ក្រាម សម្រាប់វិភាគរកភាពសុទ្ធ គ្រាប់ពូជដំណាំផ្សេង (គ្រាប់ពូជស្រូវផ្សេង ស្រូវក្រហម និងគ្រាប់ពូជដំណាំផ្សេង) គ្រាប់ពូជស្មៅ សំណើមគ្រាប់ពូជ កម្ទេចកម្ទីផ្សេងទៀត និងដំណុះគ្រាប់ពូជ។ ទម្ងន់២០០ក្រាមដែលនៅសល់ត្រូវរក្សាទុកសម្រាប់វិភាគសាឡើងវិញ ក្នុងករណីចាំបាច់។

## ផ្នែកទី៥៖ ស្តង់ដារគុណភាពគ្រាប់ពូជស្រូវតាមថ្នាក់

**ប.គ.ព** ប្រើប្រាស់ស្តង់ដារគុណភាពគ្រាប់ពូជស្រូវ ដែលរៀបចំដោយអគ្គនាយកដ្ឋានកសិកម្ម ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៨។

តារាង៖ ស្តង់ដារគុណភាពគ្រាប់ពូជស្រូវតាមថ្នាក់នីមួយៗ

| កត្តា | ស្តង់ដារតាមថ្នាក់គ្រាប់ពូជនីមួយៗ | | |
|---|---|---|---|
| | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | ពូជគ្រាប់វិញ្ញាបនបត្រ |
| ១គ្រាប់ពូជសុទ្ធ (% អប្បបរមា) | ៩៨ | ៩៨ | ៩៨ |
| ២. កម្មេចកម្ទី (% អតិបរមា) | ២ | ២ | ២ |
| - គ្រាប់ស្មៅ (ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ៣ | ៥ | ១០ |
| - គ្រាប់ដំណាំដទៃ (ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ២ | ៣ | ៥ |
| - គ្រាប់ស្រូវផ្សេង (ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ១ | ៥ | ១៥ |
| - គ្រាប់ស្រូវអង្ករក្រហម (ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ០ | ២ | ៥ |
| ៣. ដំណុះគ្រាប់ (% អប្បបរមា) | ៨៥ | ៨៥ | ៨០ |
| ៤. សំណើមគ្រាប់ (% អតិបរមា) | ១២ | ១៣ | ១៤ |

## ផ្នែកទី៦៖ ស្លាកសញ្ញាបញ្ជាក់គុណភាព ប.គ.ព

ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.ព** គឺជាស្លាកសញ្ញាដែលត្រូវបានបង្កើត និងប្រើប្រាស់ដោយ **អគ្គនាយកដ្ឋានកសិកម្ម** ដើម្បីផ្តល់ជូន**អ្នកផលិតគ្រាប់ពូជ** បន្ទាប់ពីឡូត៍គ្រាប់ពូជបានឆ្លងកាត់ការត្រួតពិនិត្យគុណភាពស្របតាមស្តង់ដារទីវាល និងស្តង់ដារគុណភាពគ្រាប់ពូជស្រូវ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ

ឈ្មោះអ្នកស្នើសុំ៖ ........................................................................................ ភេទ៖ ...............

ឈ្មោះអង្គភាព/គ្រឹះស្ថាន៖ .............................................. តួនាទី៖ .............................................

អាសយដ្ឋាន៖ ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ................... ខេត្ត/រាជធានី...............

លេខទូរស័ព្ទ៖ (ទី១).......................................... (ទី២).........................................................

អ៊ីម៉ែល៖........................................................... តេឡេក្រាម៖..................................................

ឈ្មោះអ្នកទទួលខុសត្រូវចំពោះផលិតកម្មគ្រាប់ពូជ៖ ......................................................................

ចំនួនសមាជិកចូលរួមនៅក្នុងផលិតកម្មគ្រាប់ពូជ៖...........................នាក់ ក្នុងនោះស្ត្រីមាន៖...........នាក់

### ១. ការបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលស្តីពីផលិតកម្មគ្រាប់ពូជ (✓)៖ ធ្លាប់បានទទួល ☐ មិនធ្លាប់បានទទួល ☐

| ល.រ | អង្គភាពផ្តល់វគ្គបណ្តុះបណ្តាល | ឆ្នាំ | ចំនួនសមាជិក |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |

### ២. បទពិសោធន៍

ចំនួនឆ្នាំនៃបទពិសោធន៍ក្នុងផលិតកម្មគ្រាប់ពូជស្រូវ (ដូចមានឯកសារជូនភ្ជាប់មកជាមួយ)៖....................

ប្រភេទគ្រាប់ពូជស្រូវដែលសមាជិកក្រុមធ្លាប់ផលិត៖.......................................................................

### ៣. ប្រវត្តិនៃការផលិតគ្រាប់ពូជស្រូវ

ផ្ទៃដីនិងបរិមាណគ្រាប់ពូជបានផលិតក្នុងរយៈពេល៣(បី)ឆ្នាំចុងក្រោយ៖

| ឈ្មោះពូជ | ឆ្នាំ២០......... | | ឆ្នាំ២០......... | | ឆ្នាំ២០......... | |
|---|---|---|---|---|---|---|
| | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន |
| ១. | | | | | | |
| ២. | | | | | | |
| ៣. | | | | | | |
| ៤. | | | | | | |
| ៥. | | | | | | |
| សរុប | | | | | | |

## ៤. គ្រឿងបរិក្ខា

មានឬអាចរកជួលបានសម្រាប់ផលិតកម្មគ្រាប់ពូជ៖

| គ្រឿងបរិក្ខា | ផ្ទាល់ខ្លួន (✓) | ជួលគេ (✓) | កំណត់សម្គាល់ |
|---|---|---|---|
| ត្រាក់ទ័រ | | | |
| គោយន្ត | | | |
| នង្គ័ល | | | |
| ម៉ាស៊ីនវាយដី (រ៉ូតាវ៉ាទ័រ) | | | |
| ម៉ាស៊ីនស្ទូង | | | |
| ឧបករណ៍/ម៉ាស៊ីនដាំគ្រាប់ពូជជាជួរ | | | |
| ឧបករណ៍/ម៉ាស៊ីនបាញ់ថ្នាំ | | | |
| សម្ភារការពារខ្លួន | | | |
| ម៉ាស៊ីនច្រូត | | | |
| ឡសម្ងួត (សូមបញ្ជាក់ប្រភេទ) | | | |
| ម៉ាស៊ីនសម្អាតគ្រាប់ពូជ | | | |
| ម៉ាស៊ីនបក់គ្រាប់ពូជ | | | |
| ជញ្ជីង | | | |
| កំណល់(ប៉ាឡែត) | | | |
| រទេះរុញ | | | |
| ឧបករណ៍វាស់សំណើម | | | |
| ឃ្លាំងសម្រាប់រក្សាគ្រាប់ពូជ | ..............ម២ | ..............ម២ | សរុប៖............................... ម២ |
| ផ្សេងទៀត (សូមបញ្ជាក់) | | | |

## ៥. ផែនការផលិតកម្មគ្រាប់ពូជសរុបសម្រាប់៣(បី)ឆ្នាំ៖ ..................................... (ហ.ត)

| ទីតាំងផលិតកម្ម | ឆ្នាំ២០.......................... | | | ឆ្នាំ២០.......................... | | | ឆ្នាំ២០.......................... | | |
|---|---|---|---|---|---|---|---|---|---|
| | ដើមរដូវវស្សា | រដូវវស្សា | រដូវប្រាំង | ដើមរដូវវស្សា | រដូវវស្សា | រដូវប្រាំង | ដើមរដូវវស្សា | រដូវវស្សា | រដូវប្រាំង |
| ១. | | | | | | | | | |
| ២. | | | | | | | | | |
| ៣. | | | | | | | | | |
| ៤. | | | | | | | | | |
| ៥. | | | | | | | | | |
| សរុប | | | | | | | | | |

**៦. ឯកសារជូនភ្ជាប់៖**

ក. វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលផលិតកម្មគ្រាប់ពូជស្រូវ ☐

ខ. កិច្ចសន្យាផលិតកម្មកន្លងមក (ប្រសិនបើមាន) ☐

គ. រចនាសម្ព័ន្ធធុរកិច្ចគ្រាប់ពូជស្រូវ ☐

ខ្ញុំសូមធានាអះអាងចំពោះអង្គភាពមានសមត្ថកិច្ចថា រាល់ព័ត៌មានខាងលើពិតជាត្រឹមត្រូវ និងសូមសន្យាអនុវត្តផលិតកម្មគ្រាប់ពូជស្រូវតាមគោលការណ៍ប្រព័ន្ធធានាគុណភាពពូជដំណាំ (**ប.គ.៣**)។

ធ្វើនៅ......................, ថ្ងៃទី.........../.........../................

ហត្ថលេខានិងឈ្មោះអ្នកស្នើសុំ៖

.................................................................

## ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

# លិខិតអនុញ្ញាត
# ធ្វើអាជីវកម្មផលិត កែច្នៃពូជដំណាំ

លេខ៖......................................អ.ន.ក

## អគ្គនាយកដ្ឋានកសិកម្ម

- បានឃើញព្រះរាជក្រម លេខ **នស/រកម/០៥០៨/០១៥** ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញប្រកាស លេខ**៣៧៥ ប្រក.កសក** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីគំរូពាក្យស្នើសុំនិងនីតិវិធីនៃការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ
- បានឃើញពាក្យស្នើសុំលេខ......................................... ចុះថ្ងៃទី................. ខែ................. ឆ្នាំ២០...........

## សម្រេច

**អនុញ្ញាតឱ្យ៖** លោក/លោកស្រី.................................................................................. មុខងារ...................................................................................................

ក្រុមហ៊ុនឬនីតិបុគ្គល..........................................................................................................................................................................................................

**ធ្វើអាជីវកម្មផលិតកែច្នៃពូជដំណាំ** ................................................................... ដែលមានសមត្ថភាពផលិតកែច្នៃពូជដំណាំប្រចាំឆ្នាំ................................................./ឆ្នាំ។

អាសយដ្ឋានរបស់គ្រឹះស្ថាន..................................................................................................................................................................................។

**សុពលភាព៖** លិខិតអនុញ្ញាតនេះត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំ ដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំជាធរមានក្នុងសុពលភាពរយៈពេល **៣**ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ និងត្រូវផុតសុពលភាពនៅថ្ងៃទី........... ខែ........... ឆ្នាំ២០........... លើកលែងតែមានការដកហូតដោយអគ្គនាយកដ្ឋានកសិកម្ម នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រាជធានីភ្នំពេញ ថ្ងៃទី.............. ខែ.............. ឆ្នាំ២០........

**អគ្គនាយក**

## ឧបសម្ព័ន្ធទី៣

## ទម្រង់ (ក)៖ ផែនការផលិតកម្មគ្រាប់ពូជស្រូវប្រចាំរដូវ

១. ឈ្មោះអ្នកស្នើសុំ៖ ........................................................................................ ភេទ៖ ...............

២. ឈ្មោះអង្គភាព/គ្រឹះស្ថាន៖ ....................................................... តួនាទី៖ ..................................

៣. អាសយដ្ឋាន៖ ភូមិ............... ឃុំ/សង្កាត់............... ស្រុក/ខណ្ឌ................. ខេត្ត/រាជធានី..............

៤. លេខទូរស័ព្ទ៖ (ទី១)...................................... (ទី២)........................................................

៥. អ៊ីម៉ែល៖...................................................... តេឡេក្រាម៖..................................................

៦. លេខលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ៖.................................. ចុះថ្ងៃទី......./......../.............

៧. រដូវដាំដុះ៖...........កាលបរិច្ឆេទចាប់ផ្ដើមដាំដុះ៖....................កាលបរិច្ឆេទគ្រោងប្រមូលផល៖.........

៨. ព័ត៌មានស្ដីពីផលិតកម្មគ្រាប់ពូជ៖

| ល.រ | ឈ្មោះពូជ | ថ្នាក់គ្រាប់ពូជ | ផ្ទៃដី(ហ.ត) | ចំនួនស្រែ | ទីតាំងផលិតកម្ម |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| | សរុប | | | | |

៩. ព័ត៌មានស្ដីពីប្រភពគ្រាប់ពូជប្រើប្រាស់ក្នុងផលិតកម្មគ្រាប់ពូជ

| ល.រ | ឈ្មោះពូជ | ថ្នាក់គ្រាប់ពូជ | បរិមាណ(គ.ក្រ) | លេខឡូតិ៍ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| | សរុប | | | |

*✵កំណត់សម្គាល់៖ អ្នកផលិតគ្រាប់ពូជត្រូវរក្សាទុករាល់ស្លាកសំណៅដើម បាវវេចខ្ចប់ វិក្កយបត្រទិញគ្រាប់ពូជសម្រាប់ផ្ទៀងផ្ទាត់ដោយស្ថាប័នមានសមត្ថកិច្ច។*

១០. ឯកសារជូនភ្ជាប់ (សូមមើលតារាងគំរូ)

ខ្ញុំសូមធានាអះអាងចំពោះអង្គភាពមានសមត្ថកិច្ចថា រាល់ព័ត៌មានខាងលើពិតជាត្រឹមត្រូវ។ ក្នុងករណីស្រែផលិតកម្មគ្រាប់ពូជខូចខាត ឬប្រែប្រួលដោយប្រការណាមួយ ខ្ញុំនឹងជូនដំណឹងទៅអង្គភាពមានសមត្ថកិច្ច។

ធ្វើនៅ......................., ថ្ងៃទី.........../.........../................

ហត្ថលេខានិងឈ្មោះអ្នកស្នើសុំ៖

..................................................................

## គំរូឯកសារជូនភ្ជាប់៖ បញ្ជីឈ្មោះសមាជិកក្រុមផលិតគ្រាប់ពូជស្រូវ

| ល.រ | ឈ្មោះ | ភេទ | កូដ អ្នកផលិត | ពូជ ផលិត | ថ្នាក់ គ្រាប់ពូជ | ផ្ទៃដីផលិត (ហ.ត) | ចំនួន ស្រែ | ផ្ទៃដីស្រែ នីមួយៗ | កូដស្រែ |
|---|---|---|---|---|---|---|---|---|---|
| ១ | អឹម សេរី | ប | G001 | PRD | CS | 1.2 | 2 | 0.7 | G001F01 |
| | | | | | | | | 0.5 | G001F02 |
| ២ | លឹម លាភ | ស | G002 | SKO | CS | 2.2 | 2 | 1.2 | G002F01 |
| | | | | | | | | 1.0 | G002F02 |

# ឧបសម្ព័ន្ធទី៤

## របាយការណ៍ត្រួតពិនិត្យគុណភាពផលិតកម្មទីវាល

លេខកូដស្រែ.................................................... លេខរបាយការណ៍ .........................................

កាលបរិច្ឆេទត្រួតពិនិត្យ........./........../.................. ពេលវេលាៈពីម៉ោង..............ដល់ម៉ោង.............

ឈ្មោះពូជស្រូវ.................................................. ថ្នាក់គ្រាប់ពូជ................................................

កាលបរិច្ឆេទដាំ/ស្ទូង.........../........../.................... កាលបរិច្ឆេទគ្រោងប្រមូលផល......../......../........

១. ឈ្មោះកសិករផលិត....................................... ភេទ............... កូដកសិករផលិត.......................

២. អាសយដ្ឋានៈ ភូមិ............. ឃុំ/សង្កាត់.............. ស្រុក/ខណ្ឌ............... ខេត្ត/រាជធានី...................

៣. ទីតាំងស្រែ.......................................................................................................................

៤. ប្រភពគ្រាប់ពូជ............................................. កាលបរិច្ឆេទទិញ............................................

៥. ផ្ទៃដីផលិតកម្មគ្រាប់ពូជសរុបនៃពូជស្រូវខាងលើ...........................................................(ហិកតា)

៦. ផ្ទៃដីស្រែត្រូវត្រួតពិនិត្យ........................................................................................(ហិកតា)

៧. ប្រភេទដំណាំបានដាំពីមុននៅក្នុងស្រែ..................................... គម្លាតពីស្រែជុំវិញ......................

៨. ដំណាក់កាលស្រូវពូជខាងលើនៅពេលត្រួតពិនិត្យ.........................................................................

៩. លទ្ធផលតាមសំណាក (អនុវត្តតាមគោលការណែនាំ)

| **លេខរៀងសំណាក** | **☐ ចំនួនដើម(លើកទី១) ☐ ចំនួនកួរ(លើកទី២)** | | **ភាគរយ** |
|---|---|---|---|
| | **ពូជលាយ** | **ស្មៅហាមឃាត់** | **ជំងឺហាមឃាត់** |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| ៦. | | | |
| ៧. | | | |
| ៨. | | | |
| ៩. | | | |
| ១០. | | | |
| **សរុប** | | | |

១០. ឈ្មោះ

(ក) ជំងឺហាមឃាត់ៈ ប្លាស់ ☐ អុចត្នោត ☐ រលាកស្រទបស្លឹក ☐

(ខ) ប្រភេទស្មៅហាមឃាត់...................................................................................................

១១. ស្ថានភាពដំណាំ..............................................................................................................

១២. តើស្រែផលិតកម្មគ្រាប់ពូជនេះអនុលោមតាមស្តង់ដារទីវាលដែរឬទេ ?.........................................
១៣. គុណភាពនៃការងារផលិតកម្មគ្រាប់ពូជ........................................................................
១៤. តើនេះជារបាយការណ៍ចុងក្រោយមែនទេ ?...................................................................
១៥. ទិន្នផលគ្រាប់ពូជត្រូវបានប៉ាន់ប្រមាណ...................................................... ( តោន/ហិកតា )
១៦. តើអ្នកផលិត ឬតំណាងរបស់គាត់មានវត្តមានក្នុងពេលត្រួតពិនិត្យដែរឬទេ ?.................................
១៧. កំណត់សំគាល់/សេចក្តីសន្និដ្ឋាន/អនុសាសន៍..................................................................
.........................................................................................................................
.........................................................................................................................
.........................................................................................................................
.........................................................................................................................
.........................................................................................................................

ហត្ថលេខាអ្នកផលិតគ្រាប់ពូជ

ហត្ថលេខាមន្ត្រីត្រួតពិនិត្យគុណភាព

ឈ្មោះ

ឈ្មោះ

# ឧបសម្ព័ន្ធទី៥

## ទម្រង់ (ខ)៖ សំណើសុំត្រួតពិនិត្យគុណភាពគ្រាប់ពូជ

១. ឈ្មោះអ្នកស្នើសុំ៖ ................................................................................. ភេទ៖ ...............

២. ឈ្មោះអង្គភាព/គ្រឹះស្ថាន៖ ....................................................តួនាទី៖ ................................

៣. អាសយដ្ឋាន៖ ភូមិ............... ឃុំ/សង្កាត់............... ស្រុក/ខណ្ឌ................. ខេត្ត/រាជធានី..............

៤. លេខទូរស័ព្ទ៖ (ទី១)...................................... (ទី២)........................................................

៥. អ៊ីម៉ែល៖...................................................... តេឡេក្រាម៖...............................................

៦. លេខលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ៖................................... ចុះថ្ងៃទី......./........./.............

៧. ជម្រើសនៃការត្រួតពិនិត្យគុណភាព (សូមគូសយកតែមួយប៉ុណ្ណោះ)៖

ក. ១០%នៃឡូតិ៍គ្រាប់ពូជសរុបនៃពូជនីមួយៗ ☐

ខ. គ្រប់ឡូតិ៍គ្រាប់ពូជទាំងអស់ ☐

| ល.រ | ឡូតិ៍គ្រាប់ពូជ | បរិមាណ (គ.ក្រ) | ឈ្មោះពូជ | ថ្នាក់គ្រាប់ពូជ | ចំនួនបាវសម្រាប់ផ្តល់ស្លាកសញ្ញាបញ្ជាក់ គុណភាព ប.គ.ព |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| **សរុប** | | | | | |

*<u>✵កំណត់សម្គាល់៖</u> ក្នុងករណីឡូតិ៍គ្រាប់ពូជមានចំនួនច្រើន សូមភ្ជាប់បន្ថែមតាមតារាងគំរូខាងលើ។*

៨. គ្រាប់ពូជត្រូវបានដាក់ថ្នាំខ្ទូតនៅថ្ងៃទី....... ខែ........ ឆ្នាំ................ ដោយប្រើថ្នាំឈ្មោះ ......................
បានរយៈពេល..........ម៉ោង ឬ............. ថ្ងៃ។

ខ្ញុំសូមធានាអះអាងថា គ្រាប់ពូជនៃឡូតិ៍នីមួយៗត្រូវបានផលិតស្របតាមលក្ខខណ្ឌតម្រូវនៃប្រព័ន្ធធានាគុណភាពពូជដំណាំ (**ប.គ.ព**)។

ខ្ញុំសូមគោរពអញ្ជើញមន្ត្រីមានសមត្ថកិច្ចចុះមកត្រួតពិនិត្យគុណភាពគ្រាប់ពូជដោយក្តីអនុគ្រោះ។

ធ្វើនៅ......................, ថ្ងៃទី........./........./................

ហត្ថលេខានិងឈ្មោះអ្នកស្នើសុំ

..................................................................

# គំនូសបំព្រួញនីតិវិធី ប.គ.ព សម្រាប់ផលិតកម្ម និងអាជីវកម្មគ្រាប់ពូជស្រូវ



# សទ្ទានុក្រម

**ប្រព័ន្ធធានាគុណភាពពូជដំណាំ (ប.គ.ព)** (Quality Declared Seed-QDS System)

ប្រព័ន្ធធានាគុណភាពពូជដំណាំ ដែលសរសេរអក្សរកាត់ **ប.គ.ព** ជាប្រព័ន្ធធានាការបញ្ជាក់គុណភាពពូជដំណាំគ្រប់ប្រភេទដែលបានចុះបញ្ជីស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ផលិតកម្មពូជដំណាំ នៅក្នុងស្រុក ការធ្វើអាជីវកម្ម ឬការធ្វើចរាចរណ៍លើទីផ្សារនៅក្នុងប្រទេសឬការធ្វើពាណិជ្ជកម្មក្រៅប្រទេស។

**អង្គភាពមានសមត្ថកិច្ច** (Competency authority-CA)

អង្គភាពមានសមត្ថកិច្ច(CA) គឺសំដៅលើ**នាយកដ្ឋានពូជដំណាំ**នៃអគ្គនាយកដ្ឋានកសិកម្ម និង**មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទរាជធានី-ខេត្ត**។

**មន្ត្រីទទួលបន្ទុក**

មន្ត្រីទទួលបន្ទុកគឺជាមន្ត្រីនៃ**នាយកដ្ឋានពូជដំណាំ** ដែលមានតួនាទីសំខាន់រៀបចំទុកដាក់ឯកសារពាក់ព័ន្ធទាំងអស់ដែលបានបញ្ជូនមក ព្រមទាំងកត់សម្គាល់ និងវាយតម្លៃអ្នកស្នើសុំជូន**អគ្គនាយកដ្ឋានកសិកម្ម** ដើម្បីធ្វើការសម្រេចចិត្តអនុញ្ញាត ផ្តល់អនុសាសន៍កែតម្រូវ ឬបដិសេធផ្តល់ជូនលិខិតអនុញ្ញាតធ្វើអាជីវកម្មពូជដំណាំ និងផ្តល់ស្លាកសញ្ញាបញ្ជាក់គុណភាព **ប.គ.ព** ជូនអ្នកស្នើសុំ។

**គ្រាប់ពូជគ្រឹះ** (Foundation Seed - FS)

សំដៅដល់ពូជដំណាំជំនាន់ក្រោយនៃពូជជម្រើសវិទូតាមវិធីសាស្ត្រស្ទូងជាជួរ មួយដើមក្នុងមួយដំណោត និងឋិតក្រោមការគ្រប់គ្រងផ្ទាល់របស់រុក្ខជម្រើសវិទូ ឬអ្នកផលិតគ្រាប់ពូជស្របច្បាប់។ ថ្នាក់គ្រាប់ពូជគ្រឹះ ត្រូវបានផលិតក្រោមវិធានទទួលស្គាល់ដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំក្នុងគោលបំណងរក្សាភាពសុទ្ធពន្ធុ និងអត្តសញ្ញាណរបស់ប្រភេទពូជតាមស្តង់ដារគុណភាពគ្រាប់ពូជ។

**គ្រាប់ពូជបញ្ជី** (Registered Seed - RS)

សំដៅដល់ពូជដំណាំដែលបានផលិតចេញពីគ្រាប់ពូជគ្រឹះដោយវិស័យសាធារណៈ ឬវិស័យឯកជន តាមវិធីសាស្ត្រដាំជាជួរ ឬស្ទូងជាជួរ១-៣ដើមក្នុងមួយដំណោត និងឋិតនៅក្រោមវិធានដែលទទួលស្គាល់ដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពន្ធុនិងអត្តសញ្ញាណរបស់ប្រភេទពូជតាមស្តង់ដារគុណភាពគ្រាប់ពូជ។

### គ្រាប់ពូជវិញ្ញាបនបត្រ (Certified Seed - CS)

សំដៅដល់ពូជដំណាំដែលបានផលិតពីគ្រាប់ពូជចុះបញ្ជីដោយអ្នកផលិតគ្រាប់ពូជ ឬស្ថានីយ៍អភិវឌ្ឍន៍កសិកម្មសាធារណៈតាមវិធីសាស្ត្រដាំជាជួរ ឬស្ទូងធម្មតា១-៣ដើមក្នុងមួយដំណោត និងឋិតនៅក្រោមវិធានទទួលស្គាល់ដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពន្ធុនិងអត្តសញ្ញាណរបស់ប្រភេទពូជតាមស្តង់ដារគ្រាប់ពូជ។

### សមាគមវិភាគពូជដំណាំអន្តរជាតិ (International Seed Testing Association-ISTA) ឆ្នាំ2018

សហគមវិភាគពូជដំណាំអន្តរជាតិ (ISTA) មានវិធានគោលការណ៍បច្ចេកទេសដែលត្រូវបានប្រើប្រាស់សម្រាប់យកសំណាក និងវិភាគគុណភាពគ្រាប់ពូជដំណាំ។